ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០១៨

**សេចក្តីផ្តើម :**

នៅក្នុងខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:**

**១.មុខងារនីតិកម្ម:**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០១លើក សម័យប្រជុំពេញអង្គព្រឹទ្ធសភានីតិកាលទី៤ចំនួន០១លើក ដើម្បីឆ្លងសេចក្តីសម្រេចស្តីពី ការបង្កើតយន្តការសំខាន់ៗសម្រាប់នីតិកាលទី៤ (ក្រុមភូមិភាគ ក្រុមសមាជិក សមាជិកាព្រឹទ្ធសភា ក្រុមពហុភាគី ក្រុមមិត្តភាព ក្រុមជនបង្គោល ក្រុមអ្នកនាំពាក្យ គណៈកម្មការក្រមសីលធម៌ និងការពិចារណាកែសម្រួលរចនាសម្ព័ន្ធ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភានីតិកាលទី៤ចំនួន០២លើក<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗសរុបចំនួន០៥លើក មានអ្នកចូលរួមចំនួន៣២១នាក់<br>- បានបញ្ជូនលិខិតទៅក្រៅស្ថាប័នព្រឹទ្ធសភាចំនួន ១៨ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៥០លើក |

| | |
|---|---|
| | - បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័នចំនួន១៨២នាក់ ស្មើនឹង០២លើក<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និងលិខិតផ្សេងៗចំនួន៣១ច្បាប់<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗ ចំនួន៣៦១ច្បាប់ពីក្រសួង ស្ថាប័ននានា និងចាត់ចែងតាមនីតិវិធី<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៥ច្បាប់<br>- បានរៀបចំទីកន្លែងប្រជុំ ធ្វើលិខិតអញ្ជើញចំនួន០២លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេងចំនួន១៣លើក<br>- បានសិក្សាលើកម្មវិធីថ្មី Streaming Media សម្រាប់បម្រើជូនសមាជិក សមាជិកាព្រឹទ្ធសភា នាពេលប្រជុំពេញអង្គ និងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន២០លើក ។ |

**២.មុខងារតំណាង** :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា៖<br>+ អញ្ជើញជាគណៈអធិបតីក្នុងព្រះរាជពិធីប្រត់ព្រះនង្គ័ល ក្រោមព្រះរាជាធិបតីភាព **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ** | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្សការផ្សេងៗសរុបចំនួន២៨៨លើក |

| | |
|---|---|
| នពោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅទីព្រះស្រែ ភូមិស្រះវង់ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង<br>+ អញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ថ្វាយព្រះពរបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នពោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង<br>+ អញ្ជើញជាអធិបតីក្នុងពិធីបើក និងបិទអង្គសិក្ខាសាលាស្តីពី ការផ្តល់ព័ត៌មានបឋមសម្រាប់សមាជិក សមាជិកាព្រឹទ្ធសភា នីតិកាលទី៤ អំពីតួនាទី ភារកិច្ច សមត្ថកិច្ច និងយន្តការទាំងឡាយរបស់ព្រឹទ្ធសភា<br>+ អញ្ជើញជាអធិបតីក្នុងពិធីប្រារព្ធបុណ្យវិសាខបូជានៅបរិវេណព្រះមហាសក្យមុនីចេតីយ ភ្នំព្រះរាជទ្រព្យ ខេត្តកណ្តាល<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រារព្ធទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ឧសភា លើកទី១៥៥ ក្រោមប្រធានបទ កាកបាទក្រហមកម្ពុជា មានគ្រប់ទីកន្លែងសម្រាប់គ្រប់ៗគ្នាដោយមិនទុកនរណាម្នាក់ចោល<br>+ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធឆ្លងសមិទ្ធផលនានា នៅវត្តសារាយអណ្តែត | - បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងការចុះបេសកកម្មអមដំណើរក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងដាក់សម្ពោធឲ្យប្រើប្រាស់នូវអណ្តូងទឹកស្អាត ដែលជាអំណោយរបស់គណៈកម្មការទី៩ព្រឹទ្ធសភា នៅខេត្តពោធិ៍សាត់<br>- បានធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាក្រុង ស្រុក ឃុំ និងសង្កាត់ថ្មី<br>- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា និងក្នុងពិធីផ្សេងៗចំនួន០៩លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៧៩នាក់ ស្មើនឹង៣៥ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន០៣រូប ស្មើនឹង០៣ច្បាប់<br>- ថតចម្លងឯកសារបានចំនួន៩២៦ច្បាប់ អស់ក្រដាសចំនួន២៤០៦សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១៥១នាក់ ស្មើនឹង៦៥លើក<br>- បានទទួលលិខិតចូលចំនួន៩៣៥ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១២ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា- |

| | |
|---|---|
| និងពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់អគារពាណិជ្ជកម្ម និងសណ្ឋាគារ នៅខេត្តព្រះសីហនុ<br>+ អញ្ជើញនាំយកទេយ្យវត្ថុ និងបច្ច័យទៅថ្វាយសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជាចៅអធិការវត្តបទុមវត្តី ក្នុងឱកាសបុណ្យខួបកំណើតលោកជំទាវ និងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន និងញាតិកាលទាំង៧សណ្តាន នៅរាជធានីភ្នំពេញ<br>+ អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធមជ្ឈមណ្ឌលអាពាហ៍ពិពាហ៍លាភមង្គល និងទស្សនកិច្ចនៅរោងចក្រតម្លើងនិងផលិតម៉ូតូ HONDA របស់ក្រុមហ៊ុន N.c.x.co,ltd នៅរាជធានីភ្នំពេញ<br>+ អញ្ជើញដឹកនាំគណៈប្រតិភូគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី២ គោរពវិញ្ញាណក្ខន្ធ និងជាអធិបតីក្នុងពិធីជូនភ្លើងបូជាសព ឯកឧត្តម **អៀវ បណ្ណាការ** អតីតសមាជិកព្រឹទ្ធសភា និងចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពមហាឧបាសិកា **ព្រំ ផេង** ដែលត្រូវជាម្តាយក្មេករបស់ឧកញ៉ា **ឈុន អូន** និងលោកជំទាវ**សេង ចន្ថា** និងគ្រួសារសពលោកតាត **រស្មី** ដែលត្រូវជាកូនបង្កើតរបស់ឯកឧត្តមកិត្តិបរិក្សបណ្ឌិត **គាត ឈន់** នៅរាជធានីភ្នំពេញ<br>+ អញ្ជើញចុះជួបសំណេះសំណាលជាមួយ | ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១១៩លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង០២លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០២លើក<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៥នាក់<br>- បានផ្តល់អត្តបទ និងរូបថតចំនួន៣៥១សន្លឹក ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន៩២នាក់ ខ្ចីសៀវភៅចំនួន៣៩ក្បាល និងសងវិញចំនួន៣៩ក្បាល<br>- បានទទួលឯកសារ សៀវភៅ ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងព្រឹត្តិបត្រ ទស្សនាវដ្តី និងរាជកិច្ច ពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៨២ក្បាល និងកាសែតចំនួន១២១ច្បាប់<br>- កំពុងរៀបចំផលិតសៀវភៅនិនានុលេខន៍ និងសៀវភៅបត់ស្តីពី ព្រឹទ្ធសភានីតិកាលទី២ ឆ្នាំ២០១៩<br>- បានរៀបចំទស្សនាវដ្តីប្រចាំខែមេសា ឆ្នាំ២០១៨<br>- បានថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន២៨លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន២៦លើក<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចរបស់សាស្ត្រាចារ្យ និងនិស្សិតមកពីសាកលវិទ្យាល័យ |

| | |
|---|---|
| សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងខេត្តកំពត<br>+ អញ្ជើញជប់លៀង និងដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំង ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅខេត្តពោធិ៍សាត់<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០២ករណី បញ្ជូនពាក្យបណ្តឹងទៅស្ថាប័នពាក់ព័ន្ធចំនួន០៦ករណី ទទួលលិខិតឆ្លើយតបពាក្យបណ្តឹងចំនួន០១ករណី ព្រមទាំងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន១១ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងចូលរួមក្នុងពិធីសម្ពោធស្រះទឹក នៅខេត្តកំពត និងខេត្តកំពង់ចាម<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញទូទាំងប្រទេសចំនួន១៥៥លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ | បាត់ដំបងចំនួន២០នាក់ ចំនួន០១លើក ។ |

| | |
|---|---|
| កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១១៣លើក។ | |

**៣.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រធានព្រឹទ្ធសភា បានទទួលជួបសម្តែងការគួរសម និងសវនាការជាមួយសមាជិកព្រឹទ្ធសភារដ្ឋវ៉ាស៊ីនតោន នៃសហរដ្ឋ-អាមេរិក និងប្រធានប្រតិបត្តិ នៃតំបន់រដ្ឋបាលពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិន និងសមាជិកការិយាល័យនយោបាយបក្សកុម្មុយនីស្តវៀតណាម និងជាអនុប្រធានអចិន្ត្រៃយ៍ទី១ រដ្ឋសភា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម<br>- ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា បានជួបសវនាការទ្វេភាគីជាមួយគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភាវៀតណាម<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតថៃ គណៈប្រតិភូចិន គណៈប្រតិភូវៀតណាម សមាជិកព្រឹទ្ធសភាបារាំង លេខាធិការគណៈកម្មការសេដ្ឋកិច្ច និងជាសមាជិកក្រុមសភានិយាយភាសាបារាំង (APF) ចូលជួបសវនាការ និងពិភាក្សាការងារ<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមសិក្ខាសាលាសមាជិកសភាក្នុងតំបន់ស្តីពីពាណិជ្ជកម្មអន្តរជាតិ WTO នៅប្រទេសសិង្ហបុរី | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអគ្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងសវនាការចំនួន០៣លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចចំនួន២៥លើក<br>- បានរៀបចំសម្អាត តុបតែងសាល និងផ្តល់សេវាភេសជ្ជៈ និងផ្គត់ផ្គង់សម្ភារៈអនាម័យក្នុងពិធីផ្សេងៗចំនួន១៦លើក ស្មើនឹង៧៥៣នាក់<br>- បានថតចម្លងឯកសារចំនួន៤៥០ច្បាប់ អស់ក្រដាសចំនួន៤៨២០សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១៨នាក់ ស្មើនឹង១២លើក<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតធ្វើសំណើ និងលិខិតឆ្លើយតបទៅក្រសួងផ្សេងៗ និងបណ្តាអគ្គទូតនានាចំនួន១៦លើក |

| | |
|---|---|
| និងចូលរួមសមាជជនជាតិភាគតិចមូស្លីមអន្តរជាតិក្រោមប្រធានបទស្តីពី អនាគតជនជាតិភាគតិចមូស្លីម "ឱកាស និងបញ្ហាប្រឈម" នៅប្រទេសអារ៉ាប់រួម ។ | - ធ្វើលិខិតទៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំជំនួយស្មារតីចំនួន ០៣លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០នាក់ ស្មើនឹង០៤ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន០៨លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៥២នាក់ ស្មើនឹង០៤លើក<br>- បានទំនាក់ទំនងជាមួយស្ថានទូតបារាំង សមាគមបេសកកម្មសិក្សាអាស៊ី ក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅព្រឹត្តិបត្រ សម្រួលដល់កិច្ចការអន្តរជាតិ និងដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ<br>- បានអញ្ជើញទៅចូលរួមទស្សនកិច្ចដកពិសោធន៍អំពីគោលការណ៍ប្រតិបត្តិល្អក្នុងការរៀបចំការវាយតម្លៃលើផលទាក់ទងរបស់លិខិតបទដ្ឋានគតិយុត្តិ នៅប្រទេសកាណាដា ។ |

**៤.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៩៣ច្បាប់<br>- បានប្រជុំកែសម្រួលអំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច |

| | |
|---|---|
| | របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី<br>- រៀបចំចងក្រងសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងរបាយការណ៍ព្រឹទ្ធសភាស្តីពី លទ្ធផលការងារប្រចាំខែឧសភា ឆ្នាំ២០១៨ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៧០ច្បាប់ ។<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៣៨ច្បាប់<br>- ប្រជុំពិភាក្សាការងារស្តីពី មូលនិធិគន្ធបុប្ផាកម្ពុជា<br>- ប្រជុំស្តីពី ការប្រកាសសមាសភាពអគ្គលេខាធិការរងថ្មី<br>- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- កិច្ចប្រជុំរួមជាមួយរដ្ឋសភាស្តីពី ការរៀបចំក្រមសីលធម៌សភាសម្រាប់តំណាងរាស្ត្រ ។<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស :<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅស្ថាប័នចំនួន០៤វគ្គ មានសិក្ខាកាមសរុបចំនួន៣៧រូប ។ សិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៣លើក មានសិក្ខាកាមចូលរួមចំនួន១៥៣នាក់ ។ |

+ចាត់ចែងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :

- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានប្រជុំផ្ទៃក្នុងគណៈកម្មការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ៥២សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៦២សំណើ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន០៣លើក មានអ្នកចូលរួមចំនួន១៥៥នាក់
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២៦៧លើក

| | |
|---|---|
| | - បានថតចម្លងឯកសារចំនួន៣,៥៨៥ច្បាប់ និងចងក្រងសៀវភៅចំនួន៦០ក្បាល អស់ក្រដាសចំនួន២៦,៤៣២សន្លឹក និងជួសជុលសម្អាតម៉ាស៊ីនថតចម្លងចំនួន១៣លើក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៣៨នាក់ ស្មើនឹង០៩លើក។<br>**+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់:**<br>- រៀបចំគម្រោងស្នើសុំជំនួយពីប្រទេសជាមិត្ត សម្រាប់នីតិកាលទី៤<br>- បន្តសាងសង់អគារថ្មី០១ខ្នងសម្រាប់ជាការិយាល័យ ធ្វើការបណ្តោះអាសន្ន និងសាងសង់ឃ្លាំងថ្មី នៅខាងក្រោយអគារ E<br>- បានបញ្ចប់ការជួសជុលអគារសមាជិកព្រឹទ្ធសភា (DEF) និងការបំពាក់សម្ភារៈបរិក្ខារ សម្រាប់នីតិកាលទី៤<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងប្រគល់សម្ភារៈសរុបចំនួន ៧២៩គ្រឿង<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឲ្យមានសោភ័ណភាពល្អ<br>- បន្តរៀបចំបំពាក់អំពូលប្រើដោយថាមពលព្រះអាទិត្យក្នុងបរិវេណព្រឹទ្ធសភា |

| | |
| --- | --- |
| | - បានតាំងពិព័រណ៍រូបភាព និងចងបដា ពាក្យស្លោក ធ្វើហ្វុងអក្សរចំនួន០៦លើក<br>- សហការជាមួយក្រុមហ៊ុនកំចាត់សត្វកណ្តៀរ និងសហការប្រចាំការម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យមើលការប្រើប្រាស់ទឹកភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក សរុបចំនួន៤៧លើក<br>- រៀបចំតបណ្តាញខ្សែកាបអុបទិកសម្រាប់Live វីដេអូ រាល់សកម្មភាពក្នុងកិច្ចប្រជុំសំខាន់ៗ ពីសាលប្រជុំពេញអង្គទៅសាលបណ្ណាល័យ ដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកសារពត៌មានផ្តិតយករូបភាព និងសម្លេងបានច្បាស់<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុបចំនួន៦៤គ្រឿង។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន៤៨ចំណងជើង។<br>+ការងារផ្សេងៗ:<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតវីដេអូសម្រាប់បង្ហោះលើ Alert News ចំនួន១៨៤ប្រធានបទ<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន៣៧លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទប័ណ្ណខ្ចី និងសងសៀវភៅ និងបញ្ជូនសៀវភៅដាក់នៅសាលអាន |

| | |
|---|---|
| | ព្រមទាំងជួសជុលឯកសារ សៀវភៅចាស់ៗសរុបចំនួន១៣៧ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្ដី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម E-Library បណ្ដាញ Facebook សរុបចំនួន៦,៣៣៦ក្បាល ។ |

II.**ទិសដៅការងារខែមិថុនា ឆ្នាំ២០១៨**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្ដាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា ។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមវេទិកា ALFOCOM និងវេទិកា APPF នាខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

-ការចូលរួមមហាសន្និបាត APF និង ASGPF នាខែកក្កដា នៅទីក្រុងQuebec នៃប្រទេសកាណាដា

-ការចូលរួមមហាសន្និបាត AIPA នាខែកញ្ញា នៅសាធារណរដ្ឋសិង្ហបុរី

-ការចូលរួមមហាសន្និបាត IPU និង ASGP នាខែតុលា នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស

-អញ្ជើញទៅទស្សនកិច្ចផ្លូវការក្នុងឱកាសខួប៦០ឆ្នាំ នៃទំនាក់ទំនងការទូត នាខែតុលា នៅសាធារណរដ្ឋប្រជាមានិតចិន

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ត្រៀមអនុវត្តន៍កម្មវិធីជាមួយ(APF)

-ត្រៀមចូលរួមវគ្គបណ្ដុះបណ្ដាលនានាដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC)

-ការអនុវត្ត (MOU)សហប្រតិបត្តិការជាមួយព្រឹទ្ធសភាឥណ្ឌា និងប៉ាគីស្ថាន ដើម្បីឈានទៅបង្កើតអគ្គនាយកដ្ឋានខាងការស្រាវជ្រាវ ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-ត្រៀមកសាងអគារធ្វើការបណ្ដោះអាសន្ន០១ខ្នង និងឃ្លាំង០១ខ្នង

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី សម្ភារៈបរិក្ខារអេឡិចត្រូនិច និងរថយន្ត

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្ដិសុខ សណ្ដាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្ដើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្ដុះបណ្ដាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ចាប់ផ្ដើមការសិក្សាអំពីការបង្កើតអគ្គនាយកដ្ឋានស្រាវជ្រាវ និងអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិបម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀតឆ្នាំ២០១៨

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការ

-ការត្រៀមរៀបចំផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំរំកិល (២០១៩-២០២១) និងគម្រោងថវិកាឆ្នាំ២០១៩ ។

III.**សេចក្តីសន្និដ្ឋាន**

ខែឧសភានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំចាត់ចែងការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបានយ៉ាងល្អប្រសើរ ។ ជាមួយគ្នានេះ បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ។ ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស បង្កើនសមត្ថភាពស្រាវជ្រាវភាសាបរទេសកាន់តែមានតម្រូវការធំជាងមុន ដែលត្រូវខិតខំឆ្លើយតបឲ្យបានល្អប្រសើរ ។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានការកៀរគរដៃគូឧបត្ថម្ភគាំទ្រជំនួយពីគ្រប់មជ្ឈដ្ឋានជាតិ អន្តរជាតិ សំដៅអភិវឌ្ឍន៍ធនធានមធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែទំនើប និងទាន់ការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យា រួមទាំងការរីកចម្រើនក្នុងតំបន់ និងពិភពលោក។

ជាពិសេសព្រឹទ្ធសភានីតិកាលថ្មី ត្រូវដើរតួជំនួសមុខអង្គការនីតិប្បញ្ញត្តិកម្ពុជា ក្នុងក្របខ័ណ្ឌ AIPA, APF និង IPU នាពេលខាងមុខ ។ ការបង្កើតឲ្យបាននូវរចនាសម្ព័ន្ធនយោបាយគ្រប់សព្វនៅដើមនីតិកាលទី៤ គឺជាអាទិភាពខ្ពស់ ទន្ទឹមនឹងការខិតខំឆ្លើយតបដោះស្រាយរបប និងគោលនយោបាយសព្វសារពើចំពោះសមាជិកព្រឹទ្ធសភានីតិកាលទី៤ ។

ការងាររួម បានចប់សម្រាប់ដំណាក់ការដំបូងនៃនីតិកាលទី៤ ។ អ្វីត្រូវបន្តគឺប្រក្រតីកម្មការងារ និងសុខដុមកម្មរចនាសម្ព័ន្ធថ្មី ។

អគ្គលេខាធិការដ្ឋាន ត្រូវត្រៀមគ្រប់លក្ខណៈសម្បត្តិ ដើម្បីផ្តល់សេវាឲ្យបានកាន់តែប្រសើរ និងគ្រប់តាមតម្រូវការចាំបាច់ ។ក្នុងជំហានទៅមុខត្រូវកែសម្រួលរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឲ្យសមស្របនឹងតម្រូវការថ្មីៗ ជាអាទិភាព ។/

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

អ៊ុំ_សារឹទ្ធ